# សារៈសំខាន់នៃការផ្ដល់ការគាំទ្របច្ចេកទេសការងារសង្គមកិច្ច

Better Care Network

## សេចក្ដីសង្ខេបអំពីវីដេអូ

ការគាំទ្របច្ចេកទេសការងារសង្គមកិច្ច ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាគុណភាព ការកសាងសមត្ថភាពបុគ្គលិក សង្គមកិច្ច ការដោះស្រាយបញ្ហាក្នុងករណីស្មុគស្មាញ និង ការកំណត់រកឱ្យបានឆាប់រហ័សពីដំបូងនូវវិបត្តិបាក់ស្មារតីដោយប្រយោលរបស់បុគ្គលិកសង្គមកិច្ច។ ការគាំទ្របច្ចេកទេសនេះរួមចំណែកធ្វើឱ្យលទ្ធផលកាន់តែមានភាពប្រសើរឡើង សម្រាប់កុមារ និងគ្រួសារ ការពេញចិត្តនឹងការងារ និង ការរក្សាបាននូវបុគ្គលិកសង្គមកិច្ចឱ្យនៅបន្តបម្រើការងារ។ បើទោះបីវាមានសារៈសំខាន់យ៉ាងដូច្នេះក៏ដោយ ប៉ុន្តែ កម្មវិធី និង រចនា សម្ព័ន្ធការគាំទ្របច្ចេកទេស រមែងតែងត្រូវបានមើលរំលងក្នុងការអភិវឌ្ឍកម្មវិធី និង សេវាសង្គមកិច្ច ជាពិសេសនៅក្នុងបរិបទដែល ការងារសង្គមកិច្ចគឺជាវិជ្ជាជីវៈថ្មីមួយ ឬ វិជ្ជាជីវៈដែលទើបលេចរូបរាងឡើង។

នៅក្នុងវីដេអូនេះ លោក លាង ឡូ ដែលអញ្ជើញមកពីអង្គការសង្គ្រោះកុមារប្រចាំប្រទេសកម្ពុជា ធ្វើការចែករំលែកអំពីការរៀនសូត្ររបស់គាត់មួយចំនួនដែលបានផ្ដល់នូវមូលដ្ឋានព័ត៌មាន សម្រាប់ការអភិវឌ្ឍកម្មវិធី បណ្ដុះបណ្ដាលស្ដីពីការគាំទ្របច្ចេកទេសការងារសង្គមកិច្ច សម្រាប់អង្គការសមាជិកនៃគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង (ដែលជាបណ្ដាញមួយផ្ដោតលើការគាំទ្រកុមារឱ្យរស់នៅក្នុងការចិញ្ចឹមថែទាំតាមគ្រួសារប្រកបដោយសុវត្ថិភាព)។ លោក ឡូ បានពិភាក្សាអំពីសារៈសំខាន់នៃការយល់ដឹងអំពីបរិបទដែលកម្មវិធីនឹងត្រូវបានយកមកអនុវត្ត និង របៀបដែលបរិបទបង្កឱ្យមានឥទ្ធិពលទៅលើរចនាសម្ព័ន្ធ និង ការរចនាក្របខ័ណ្ឌ ការគាំទ្រ បច្ចេកទេស។ គាត់ក៏បានចែករំលែកផងដែរអំពីហេតុផល ថាហេតុអ្វីបានជាគេចាំបាច់ត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធផ្លូវការ ជាជាងការមើលឃើញថា ការងារការគាំទ្របច្ចេកទេសរួមមានតែកិច្ចប្រជុំប៉ុណ្ណោះ។

## ចំណុចពិភាក្សា៖

### ការសិក្សាទៅលើបរិបទ

នៅក្នុងវីដេអូនេះ លោក ឡូ បាននិយាយអំពីថាមវន្តមួយចំនួនដែលអាចបង្កផលប៉ះពាល់អវិជ្ជមានទៅលើកិច្ចប្រជុំ ការគាំទ្របច្ចេកទេសការងារ សង្គមកិច្ច ជាពិសេសវាបង្កឱ្យមានការធ្លាក់ចុះនូវលទ្ធភាពសម្រេចបានគោលដៅកសាងសមត្ថភាពរបស់បុគ្គលិកសង្គមកិច្ច។ នៅក្នុង បរិបទកម្ពុជា គាត់បានកំណត់រកឃើញបញ្ហាសក្ដានុពលចំនួនពីរ ដែលត្រូវគ្រប់គ្រងក្នុងនោះរួមមានការផ្សាភ្ជាប់ “កិច្ចប្រជុំ” ទៅនឹងបទពិសោធន៍អវិជ្ជមានពីអតីតកាល និង/ឬ វិន័យ ព្រមទាំងអំណាចខុសគ្នារវាងអ្នកផ្ដល់ ការគាំទ្របច្ចេកទេស និង បុគ្គលជាកម្មវត្ថុនៃការគាំទ្របច្ចេកទេស។

### នៅក្នុងបរិបទរបស់អ្នក៖

? តើកត្តាបរិបទមួយចំនួន ដែលអាចធ្វើឱ្យធ្លាក់ចុះនូវប្រសិទ្ធភាពនៃកិច្ចប្រជុំការគាំទ្របច្ចេកទេស អាចមានអ្វីខ្លះ និងតើវាអាចបង្កឱ្យធ្លាក់ចុះប្រសិទ្ធភាពដោយរបៀបណា?

? តើអ្នកអាចរៀបចំឱ្យមានវិធានការអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាទាំងនេះដើម្បីការពារសុចរិតភាពនៃកម្មវិធីការគាំទ្របច្ចេកទេស និងគោលបំណងនៃកិច្ចប្រជុំ?

## អភិក្រមដែលមានការរៀបចំរចនាសម្ព័ន្ធ សម្រាប់ការគាំទ្របច្ចេកទេសការងារសង្គមកិច្ច

នៅក្នុងវីដេអូនេះ លោក ឡូ បានពិភាក្សាអំពីសារៈសំខាន់នៃការប្រើប្រាស់អភិក្រមដែលមានមូលដ្ឋានផ្អែកលើភាពខ្លាំង សម្រាប់ការគាំទ្របច្ចេកទេសការងារសង្គមកិច្ច។ គាត់បានគូសបញ្ជាក់អំពីរបៀបដែលអភិក្រមនេះជួយ ធានាថាកិច្ចប្រជុំមានបរិយាកាសប្រកបដោយ សុវត្ថិភាព ដែលបុគ្គលិកសង្គមកិច្ចត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងអំពីការអនុវត្ត និង បទពិសោធន៍របស់ពួកគេ ព្រមទាំងចែករំលែកការរៀនសូត្ររបស់ពួកគេផងដែរ។

## នៅក្នុងបរិបទរបស់អ្នក៖

? តើបច្ចុប្បន្នអង្គការរបស់អ្នកផ្តល់ការលើកទឹកចិត្ត និង បង្កើតឱកាសសម្រាប់បុគ្គលិកសង្គមកិច្ច ឬ អ្នកអនុវត្តការងារឱ្យឆ្លុះបញ្ចាំងអំពីបទពិសោធន៍ និង ចែករំលែកការរៀនសូត្ររបស់ពួកគេដល់កម្រិតណា? តើមានការអនុវត្តណាមួយនៅក្នុង អង្គការរបស់អ្នក ដែលបង្អាក់ទឹកចិត្តមិនឱ្យមានតម្លាភាព មិនឱ្យធ្វើការឆ្លុះបញ្ចាំង និងមិនឱ្យធ្វើការរៀនសូត្រ ដែរឬទេ? ប្រសិនបើមាន តើការអនុវត្តទាំងនោះមានអ្វីខ្លះ និង តើវាបានរាំងស្ទះដល់ការឆ្លុះបញ្ចាំង និងការរៀនសូត្រដោយរបៀបណា?

---

? តើគេអាចកែសម្រួល ឬ ធ្វើអ្វីបានខ្លះ ដើម្បីពង្រឹងសារៈសំខាន់នៃការឆ្លុះបញ្ចាំង និង ការរៀនសូត្រក្នុងការងារសង្គមកិច្ច នៅក្នុងអង្គការរបស់អ្នក បន្ថែមទៀត? តើអ្នករំពឹងថាសកម្មភាពនេះនឹងជួយកែលម្អការអនុវត្ត និង លទ្ធផលការងារសង្គមកិច្ច សម្រាប់កុមារ និងគ្រួសារបានដោយរបៀបណា? តើជំហានបន្ទាប់ក្នុងការស្វែងរកមតិគាំទ្រ ឬ អនុវត្តចំណាត់ការ ដើម្បីឱ្យមានការផ្លាស់ប្តូរទាំងនេះ មានអ្វីខ្លះ?